COVID-19 advice for families

School operations in *Greater Sydney

# ដំបូន្មានសម្រាប់ក្រុមគ្រួសារអំពី COVID-19

## ប្រតិបត្តិការសាលារៀននៅ *Greater Sydney

ក្រសួងអប់រំរដ្ឋ NSW និងក្រសួងសុខាភិបាលរដ្ឋ NSW កំពុងធ្វើការរួមគ្នាដើម្បីឆ្លើយតបទៅនឹង COVID-19។

បន្ទាប់ពីទទួលបានដំបូន្មានពីក្រសួងសុខាភិបាលរដ្ឋ NSW ការរៀនសូត្រពីផ្ទះត្រូវបានដាក់ដំណើរការសម្រាប់សាលារៀនក្នុងតំបន់ *Greater Sydney (រួមមាន Blue Mountains, Central Coast, Wollongong និង Shellharbour)។ សាលារៀនបើកសម្រាប់សិស្សទាំងអស់ ដែលត្រូវការមកសាលារៀន។ ប្រសិនបើសិស្ស ឬមាតាបិតា ឬកូនមានរោគសញ្ញា COVID-19 សូម្បីតែស្រាលបំផុតក្តី (COVID-19 symptoms) ពួកគេមិនត្រូវមកសាលារៀនទេ ហើយមិនត្រូវវិលត្រឡប់មកសាលារៀនវិញ រហូតទាល់តែពួកគេទទួលបានលទ្ធផលតេស្តអវិជ្ជមាន និងមិនមានរោគសញ្ញា។

### ម៉ាស់ និងរបាំងមុខ

ខណៈពេលនៅសាលារៀន ការពាក់ម៉ាស់ ឬរបាំងមុខ ត្រូវបានតម្រូវនៅក្នុងទីកន្លែងអគារទាំងអស់សម្រាប់៖

- សិស្សទាំងអស់ចាប់ពីថ្នាក់ទី 7 ឡើងទៅ
- បុគ្គលិកទាំងអស់។

ការលើកលែងមួយចំនួនអនុវត្តចំពោះបទបញ្ជាទាំងនេះ។ សូមយោងទៅ បទបញ្ជាស្តីពីការពាក់ម៉ាសមុខ នៅលើគេហទំព័ររបស់រដ្ឋាភិបាលរដ្ឋ NSW (Face mask rules on the NSW Government website) សម្រាប់ព័ត៌មានបន្ថែម។

### ភ្ញៀវ

ភ្ញៀវដែលមិនចាំបាច់ មិនបានអនុញ្ញាតឱ្យចូលមកទីតាំងសាលារៀនទេ។

ឪពុកម្តាយ និងអ្នកថែទាំ ត្រូវតែអនុវត្តតាមដំបូន្មានសាលារៀនរបស់ពួកគេ ទាក់ទងនឹងការផ្លាស់ប្តូរលើការយកសិស្សមក ឬយកសិស្សចេញពីសាលារៀន។ នេះរាប់បញ្ចូលទាំងការស្ថិតនៅក្នុងឡាន នៅពេលយកសិស្សមក ឬយកសិស្សចេញពីសាលារៀន ប្រសិនបើមានសុវត្ថិភាពក្នុងការធ្វើដូច្នោះ។ នេះមិនអនុវត្តចំពោះការយកសិស្សមក ឬយកសិស្សចេញពីកន្លែងថែទាំក្រៅម៉ោងសាលាទេ (Out of School Hours Care (OOSHC)) ដែលតម្រូវឱ្យមានទម្រង់ការចុះឈ្មោះចូល និងចុះឈ្មោះចេញ។

ឪពុកម្តាយត្រូវតែ៖

- ធ្វើតាមដំបូន្មានរក្សាគម្លាតរាងកាយ សម្រាប់តំបន់មូលដ្ឋានរបស់ពួកគេ និងជៀសវាងការមូលផ្តុំគ្នានៅខាងក្រៅខ្លោងទ្វារសាលារៀន
- រក្សានៅខាងក្រៅបរិវេណសាលា - ករណីលើកលែងមួយចំនួនអាចអនុវត្ត ទាក់ទិននឹងសាលារៀនសម្រាប់គោលបំណងជាក់លាក់ (Schools for Specific Purposes (SSP)) សិស្សដែលងាយរងគ្រោះ ឬសិស្សពិការ។
- ប្រកាន់ខ្ជាប់នូវតម្រូវការពាក់ម៉ាស់ និងចុះឈ្មោះចូល ដោយប្រើលេខកូដ Service NSW QR code នៅពេលចូលមកសាលារៀន។

### សិស្ស HSC

សិស្ស HSC នឹងត្រូវបានគាំទ្រឱ្យចូលមកសាលារៀនដើម្បីធ្វើវគ្គសិក្សា ការងារគម្រោង និងរៀបចំការប្រឡង ដែលកិច្ចការទាំងនេះមិនអាចធ្វើបានពីផ្ទះ។ សិស្សដែលមកសាលារៀន នឹងតម្រូវឱ្យប្រកាន់ខ្ជាប់នូវការអនុវត្តសុវត្ថិភាព COVID ដែលម៉ឺងម៉ាត់។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។



NSW GOVERNMENT